**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

*ថ្ងៃ សុក្រ ១៣ រោច ខែ ភទ្របទ ឆ្នាំ ខាល ចត្វាស័ក ព.ស. ២៥៦៦*
*រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០២២*

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# សិក្ខាសាលាស្តីពី
# តួនាទីនៃវិស័យធនាគារ និងបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងសេដ្ឋកិច្ចឌីជីថលកម្ពុជា

នារសៀលថ្ងៃទី **២២ ខែ កញ្ញា ឆ្នាំ ២០២២**, គណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល និងធនាគារជាតិនៃកម្ពុជា បានសហការរៀបចំសិក្ខាសាលាស្តីពី **"តួនាទីនៃវិស័យធនាគារ និងបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងសេដ្ឋកិច្ចឌីជីថលកម្ពុជា"** នៅសណ្ឋាគារ ហៃយ៉ាត់ រីជិនស៊ី ភ្នំពេញ។ សិក្ខាសាលានេះមានការចូលរួមពីថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, គណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល, ធនាគារជាតិនៃកម្ពុជា, សមាជិកក្រុមការងាររៀបចំសេចក្តីព្រាងគោលនយោបាយអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា, សមាគម, គ្រឹះស្ថានធនាគារ, គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងគ្រឹះស្ថានហិរញ្ញវត្ថុពាក់ព័ន្ធ សរុបចំនួន **៩០ រូប** ដែលបានចូលរួមផ្ទាល់ និង **១១០ រូប** ចូលរួមតាមប្រព័ន្ធអនឡាញ ។ សិក្ខាសាលានេះរៀបចំឡើងក្នុងគោលបំណង (១) ផ្សព្វផ្សាយគោលនយោបាយ និងក្របខណ្ឌបទប្បញ្ញត្តិកម្ពុជាទាក់ទងនឹងឌីជីថលូបនីយកម្មក្នុងវិស័យធនាគារ, (២) កំណត់និន្នាការបច្ចុប្បន្ន បញ្ហាប្រឈម និងកាលានុវត្តភាពនៃឌីជីថលូបនីយកម្មក្នុងវិស័យធនាគារនៅកម្ពុជា, និង (៣) បន្តប្រមូលធាតុចូលល្អៗបន្ថែម និងជាក់លាក់លើវិស័យហិរញ្ញវត្ថុធនាគារ ដើម្បីរៀបចំសេចក្តីព្រាងគោលនយោបាយអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា។

សិក្ខាសាលានេះត្រូវបានចាប់ផ្តើមដំណើរការដោយសុន្ទរកថាស្វាគមន៍របស់ លោក Raymond Sia Say Guan ប្រធានសមាគមធនាគារកម្ពុជា និងសុន្ទរកថាគន្លឹះរបស់ **ឯកឧត្តមបណ្ឌិត គង់ ម៉ារី** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល។ ក្នុងការថ្លែងសុន្ទរកថាគន្លឹះនេះ **ឯកឧត្តមបណ្ឌិត** បានលើកឡើងពីសក្តានុពលនៃបច្ចេកវិទ្យាហិរញ្ញវត្ថុ ទាំងនៅក្នុងការអភិវឌ្ឍវិស័យធនាគារ ក៏ដូចជាការអភិវឌ្ឍវិស័យហិរញ្ញវត្ថុមិនមែនធនាគារ និងវិស័យហិរញ្ញវត្ថុមីក្រូផងដែរ។ **ឯកឧត្តមបណ្ឌិត** បានលើកឡើងថា សកម្មភាពធំៗទាំង ៣ ក្នុងវិស័យធនាគារ ដែលរួមមាន ការទូទាត់, ការសន្សំ, និងការផ្តល់កម្ចី គឺមានភាពល្អប្រសើរ និងមានការអភិវឌ្ឍច្រើនគួរឱ្យកត់សម្គាល់។ ជាងនេះទៅទៀត **ឯកឧត្តមបណ្ឌិត** បានស្នើជាយោបល់ថា *"និន្នាការថ្មីៗ ដែលមានសក្តានុពលមួយចំនួនទៀតដែលរួមមាន ដូចជា Open Banking និងរូបិយប័ណ្ណឌីជីថលធនាគារកណ្តាល (Central Bank Digital Currency) គួរតែត្រូវបានយកចិត្តទុកដាក់បន្ថែមទៀត ដោយគិតគូរលើទិសដៅ និងគោលនយោបាយ ដើម្បីធានាបាននូវការការពារហានិភ័យ ដែលកើតចេញពីការប្រើប្រាស់បច្ចេកវិទ្យាថ្មីទាំងនេះ ។*

*Open Banking គឺសំដៅលើប្រព័ន្ធធនាគារដែលដំណើរការទាំងស្រុងនៅលើអ៊ីនធឺណិត និងមិនមានហេដ្ឋារចនាសម្ព័ន្ធរូបវន្តនោះទេ ហើយមានលក្ខណៈបើកចំហសម្រាប់ការធ្វើសន្ទានកម្មនៃកម្មវិធីកុំព្យូទ័រ (Application Programming Interface – API) ដោយអនុញ្ញាតឱ្យភ្នាក់ងារផ្តល់សេវាហិរញ្ញវត្ថុទី ៣ (Third-party) អាចចូលទៅប្រើប្រាស់ទិន្នន័យ និងធ្វើអន្តរប្រតិបត្តិការទូទាត់ឆ្លងគ្រឹះស្ថានបាន។ ចំណែកឯ រូបិយប័ណ្ណឌីជីថលធនាគារកណ្តាលគឺជាទម្រង់ថ្មីនៃរូបិយប័ណ្ណ ដែលប្រើប្រាស់បច្ចេកវិទ្យាប្លុកឆេន និងអាចប្រើប្រាស់បានតែក្នុងទម្រង់ឌីជីថល ហើយត្រូវបានដាក់ចេញ និងគ្រប់គ្រងដោយធនាគារកណ្តាល។*

សិក្ខាសាលានេះត្រូវបានប្រកាសបើកដំណើរការជាផ្លូវការ ដោយ **ឯកឧត្តម ម៉ិ ចាន់តារា** អគ្គលេខាធិការធនាគារជាតិនៃកម្ពុជា និងជាអនុប្រធានក្រុមការងាររៀបចំសេចក្តីព្រាងគោលនយោបាយអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា។ នៅក្នុងសុន្ទរកថាបើកដំណើរការជាផ្លូវការនៃសិក្ខាសាលានេះ, **ឯកឧត្តម** បានលើកឡើងថា *"ក្នុងរយៈពេលពីទសវត្សរ៍មកនេះ ប្រព័ន្ធធនាគារនៅកម្ពុជា បានរីកចម្រើនទៅមុខទាំងផ្នែកហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងគុណភាព ហើយបានដើរតួនាទីយ៉ាងសំខាន់ ក្នុងការរួមចំណែកអភិវឌ្ឍ សេដ្ឋកិច្ច និងសង្គម ព្រមទាំងជំរុញសមាហរណកម្មសេដ្ឋកិច្ចកម្ពុជានៅក្នុងតំបន់ និងពិភពលោក តាមរយៈ ការគាំទ្រនិងជំរុញកំណើនសេដ្ឋកិច្ច លើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ និងកាត់បន្ថយភាពក្រីក្រ។"* **ឯកឧត្តម** បានបន្តថា គ្រឹះស្ថានហិរញ្ញវត្ថុទាំងអស់ បានដើរតួនាទីជាអន្តរការីយ៉ាងសំខាន់ ក្នុងការផ្តល់សេវាហិរញ្ញវត្ថុបែបប្រពៃណី ហើយគ្រឹះស្ថានខ្លះបានកំពុងដាក់ឱ្យប្រើប្រាស់សេវាធនាគារបែបឌីជីថល ជាពិសេសសេវាទូទាត់សងប្រាក់ជាអេឡិចត្រូនិកដែលរួមមានដូចជា សេវាធនាគារតាមអ៊ីនធឺណិត ឬសេវាធនាគារចល័ត សេវាទូទាត់ចល័ត ប័ណ្ណទូទាត់ និងការទូទាត់តាម QR Code ជាដើម។

ក្នុងដំណើរការនៃសិក្ខាសាលាក៏មានការធ្វើបទបង្ហាញចំនួនបី និងកិច្ចពិភាក្សាចំនួនមួយដើម្បីផ្តល់នូវចំណេះដឹងទូលំទូលាយទៅលើតួនាទីនៃវិស័យធនាគារ និងបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថលកម្ពុជា។ បទបង្ហាញទាំងបីនោះ រួមមាន៖ បទបង្ហាញស្តីពី (១) "Open Finance នៅលើក្លោដ" ដោយ **លោក Akash Jain**, Principal Architect, Financial Services, APJ, Amazon Web Services, (២) បទបង្ហាញស្តីពី "រូបិយវត្ថុឌីជីថលរបស់ធនាគារកណ្តាល៖ករណីសិក្សាពីប្រទេសថៃ" **លោក Kasidit Tansanguan**, Director of Digital Currency Team, the Bank of Thailand, និង (៣) បទបង្ហាញស្តីពី «ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ និងនវានុវត្តន៍ក្នុងវិស័យធនាគារនៅកម្ពុជា» ដោយ **លោក អ៊ុក សារ៉ាត** ប្រធាននាយកដ្ឋានប្រព័ន្ធទូទាត់សងប្រាក់នៃធនាគារជាតិនៃកម្ពុជា។ សិក្ខាសាលានេះក៏មានកិច្ចពិភាក្សាលើ "សេវាធនាគារឌីជីថលនៅកម្ពុជា" ដោយមានវាគ្មិន ៣ រូបរួមមាន **លោក អ៊ុក សារ៉ាត់** ប្រធាននាយកដ្ឋានប្រព័ន្ធទូទាត់សងប្រាក់នៃធនាគារជាតិនៃកម្ពុជា, **លោក Han Peng Kwang** នាយកប្រតិបត្តិនៃធនាគារវីង, និង **លោក ចរ សុភាព** នាយកប្រតិបត្តិអភិវឌ្ឍន៍ផលិតផលនៃធនាគារអេស៊ីលីដា និងសម្របសម្រួលដោយ **លោក គា បូរាណ** ប្រធាននាយកប្រតិបត្តិនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ។

សិក្ខាសាលានេះបានប្រព្រឹត្តទៅយ៉ាងរលូន និងបញ្ចប់ដោយភាពជោគជ័យ ដោយទទួលបាននូវលទ្ធផលគាប់ប្រសើរដូចការរំពឹងទុក។ តាមរយៈការពិភាក្សា, ការចែករំលែកទស្សនាទាន, គំនិតនវានុវត្តន៍ និងបទពិសោធជាក់ស្តែងពីសំណាក់ភាគីពាក់ព័ន្ធសំខាន់ៗទាំងអស់, គណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល ប្រមូលបាននូវធាតុចូលល្អៗជាច្រើន សម្រាប់ធ្វើជាមូលដ្ឋានក្នុងការតាក់តែងសេចក្តីព្រាងគោលនយោបាយអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ប្រកបដោយប្រសិទ្ធភាព និងគ្រប់ជ្រុងជ្រោយ។